រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីថ្លែងការណ៍
# ស្តីអំពី
# ការវាយតម្លៃចំពោះលទ្ធផលបោះឆ្នោតបឋម នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤

សមាគម អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ រកឃើញថា ការផ្ទៀងផ្ទាត់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនៃ លទ្ធផលបោះឆ្នោតបឋមនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៤ គឺមានភាព ត្រឹមត្រឹមដូចគ្នា ៩៣,១% នៃលទ្ធផលនៃការរាប់សន្លឹកឆ្នោតសម្រាប់គណបក្សនយោបាយនីមួយៗ[1] បើទោះបីមានកំហុសខ្លះ គ.ជ.ប អាចត្រួតពិនិត្យ និងកែតម្រូវ។ ភាពមិនប្រក្រតី និងភាពខុសគ្នានៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(១១០២) មិនប៉ះពាល់ លទ្ធផលបោះឆ្នោតនៅតាមឃុំ/សង្កាត់ឡើយ។

សមាគម អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ ស្នើឲ្យ គ.ជ.ប ខិតខំក្នុងការដោះស្រាយបណ្តឹងរបស់គណបក្សនយោបាយទាក់ទងនឹងការរាប់សន្លឹកឆ្នោតឡើងវិញ ពិសេសដោយសារកម្រិតលំអៀងសម្លេងឆ្នោតតិចពេកដែលមិនលើសពី០,៥% ហើយមានបញ្ហានៃសន្លឹកឆ្នោតមិនបានការមានចំនួនច្រើន ដែលអាចឲ្យគូភាគីអស់ចិត្ត និងទទួលយកលទ្ធផលបោះឆ្នោតតាមឃុំសង្កាត់ទាំងនោះ។

សមាគម អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ យល់ឃើញថា នេះជាលើកទីមួយ គឺស្ថិតក្នុងស្ថានភាពវិជ្ជមាន ដែលគណបក្សប្រកួតប្រជែងសំខាន់ៗបានខិតខំប្រមូលទិន្នន័យ ហើយបានរកឃើញលទ្ធផលបោះឆ្នោតបឋមរបស់ខ្លួន។ បើទោះមានបណ្តឹងតិចតួចទាក់ទងនឹងលទ្ធផលបោះឆ្នោត គណបក្សប្រកួតប្រជែងសំខាន់មិនមានសេចក្តីថ្លែងការណ៍បដិសេធលទ្ធផលនៃការបោះឆ្នោតទេ។

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ ជាដំបូងសូមកោតសរសើរជាខ្លាំងដល់អ្នកសង្កេតការណ៍របស់ខ្លួនទាំងអស់ដែលបានចូលរួមសង្កេតការណ៍បោះឆ្នោត គ្រប់ដំណាក់នៃដំណើរការបោះឆ្នោតដូចជាការឃោសនាបោះឆ្នោត ថ្ងៃបោះឆ្នោតជាដើម និងដែលបានបញ្ជូន និងផ្ទៀងផ្ទាត់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតក្នុងស្មារតី ទទួលខុសត្រូវ និងអត់ធ្មត់។

សមាគម និងអង្គការសង្គមស៊ីវិល នៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ សូមអរគុណដល់ម្ចាស់ជំនួយ រួមទាំងអ្នកបានផ្តល់ថវិកាសប្បុរសធម៌ឧបត្ថម្ភដល់កិច្ចការងារអ្នកសង្កេតការណ៍។

[1] ចំណុចទី៤ នៃកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២)

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្ដីពីការបោះឆ្នោតឆ្នាំ២០១៧ សូមវាយតម្លៃខ្ពស់ចំពោះការផ្ដល់កិច្ចសហការរបស់ គ.ជ.ប ជាមួយអង្គការសមាគមនៃបន្ទប់ស្ថានការណ៍ ក្នុងការជួបប្រាស្រ័យទំនាក់ទំនង និងការសម្រួលកិច្ចការជាច្រើនក្នុងបុព្វហេតុតម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវនៃការបោះឆ្នោត។

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្ដីពីការបោះឆ្នោតឆ្នាំ២០១៧ ក៏សូមកោតសរសើរចំពោះនគរបាល និងកងម្លាំងរក្សាសន្តិសុខសម្រាប់ការបោះឆ្នោត ដែលបានខិតខំរក្សាសុវត្ថិភាព និងសន្តិសុខក្នុងសម័យបោះឆ្នោត។

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្ដីពីការបោះឆ្នោតឆ្នាំ២០១៧ សូមវាយតម្លៃខ្ពស់ចំពោះស្ថានទូតអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា ដែលដាក់អ្នកសង្កេតការណ៍អន្តរជាតិ ហើយបានផ្ដល់កិច្ចសហការ និងផ្ដល់ភាពកក់ក្ដៅដល់អ្នកបោះឆ្នោត និងអ្នកសង្កេតការណ៍ជាតិ ។

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្ដីពីការបោះឆ្នោតឆ្នាំ២០១៧ សូមអបអរសាទរជាថ្មីម្ដងទៀតចំពោះម្ចាស់ឆ្នោតទាំងអស់ ដែលបានចូលរួមសកម្ម និងអត់ធ្មត់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ ដែលជាដំណើរការប្រជាធិបតេយ្យនៅកម្ពុជា។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

1. លោកស្រី ធីតា ឃឹះ — នាយិកាប្រតិបត្តិ SILAKA — ០១២ ៨៣ ៨៤ ៦៤
2. លោក គល់ បញ្ញា — នាយកប្រតិបត្តិ COMFREL — ០១២ ៩៤ ២០ ១៧
3. លោក សំ គន្ធាមី — នាយកប្រតិបត្តិ NICFEC — ០១២ ៨២ ២២ ៧៣
4. លោក យង់ គិមអេង — នាយកប្រតិបត្តិ PDP-Center — ០១៦ ៨២ ៨២ ១១
5. លោក មឿន តុលា — នាយកប្រតិបត្តិ Central — ០៩៣ ៥៥ ៦៦ ៤៣
6. លោក អំ សំអាត — អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេត LICADHO — ០១២ ៣២ ៧៧ ៧០